ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៚៣

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

លេខៈ ៦១៦ សអយ

*រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦*

# ប្រកាស

## ស្តីពី

## បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស /រកម /០១០៥ /០០១ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារដែលកម្ពុជាជាសមាជិក ប្រកាសដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២
- បានឃើញប្រកាស លេខ ០៣៨ ស អ យ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងសង្គមកិច្ច

អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបង្កើតគណៈកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ

- បានឃើញប្រកាសលេខ ២១៧ ស អ យ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល ត្រូវបានរៀបចំឡើង ដើម្បីកំណត់អំពីលក្ខខណ្ឌនៃការបង្កើតមណ្ឌល ការគ្រប់គ្រងមណ្ឌល និង ការថែទាំកុមាររស់នៅក្នុងមណ្ឌល ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.-**

ការថែទាំកុមារក្នុងមណ្ឌល គឺជាការចាត់ចែងរៀបចំឱ្យកុមាររស់នៅជុំគ្នាជាក្រុម ក្រោមការថែទាំរបស់បុគ្គលិកមណ្ឌល ដែលទទួលប្រាក់បៀវត្សសម្រាប់ផ្តល់សេវាថែទាំ ដូចជា មណ្ឌលកុមារកំព្រា មណ្ឌលស្តារនីតិសម្បទា មណ្ឌលផ្តល់កិច្ចការពារដល់កុមារជាដើម ។ កុមារដែលរស់នៅក្នុងមណ្ឌលខាងលើនេះបានទទួលការថែទាំពេញលេញក្នុងរយៈពេលមួយសមស្រប ។

# ជំពូកទី ២
## លក្ខខណ្ឌនៃការបង្កើតមណ្ឌលថែទាំកុមារ

**ប្រការ ៣.-**

### សុខុមាលភាព និង ការអភិវឌ្ឍន៍របស់កុមារ

### ១. សុខភាព អនាម័យ សំលៀកបំពាក់ និង ចំណីអាហារ

**មណ្ឌលត្រូវផ្តល់ឱ្យកុមារនូវ :**

- សេវាផ្នែកវេជ្ជសាស្ត្រទាំងក្នុង និង ក្រៅមណ្ឌល រួមទាំងការចាក់ថ្នាំបង្ការ ។
- ការថែទាំផ្នែកអនាម័យ រួមទាំង សុខភាពមាត់ធ្មេញ ។
- ទឹកស្អាតគ្រប់គ្រាន់សម្រាប់ទទួលទាន គ្រប់ពេលវេលា ។
- កែវទឹកផ្ទាល់ខ្លួន ឬ កែវទឹករួមគ្នា ដែលមានអនាម័យ ។
- អាហារដល់កុមារយ៉ាងតិច ៣ដង ក្នុងមួយថ្ងៃ ។
- របបអាហារូបត្ថម្ភមានតុល្យភាព ដែលមានជាតិ ប្រូតេអ៊ីន ( សាច់ ត្រី សណ្តែកសៀង កាបូហ៊ីដ្រាត ធញ្ញជាតិ បន្លែ ។ល។ ) ។
- របបចាំបាច់សម្រាប់កុមារដែលមានតម្រូវការពិសេស ដូចជា ទារក កុមារពិការ កុមារមានជម្ងឺ ឬ កង្វះអាហារូបត្ថម្ភ កុមារដែលមានតម្រូវការអាហារតាមទំនៀមទម្លាប់ ឬ ជំនឿសាសនា ជាដើម ។
- សម្ភារៈសង្គ្រោះបឋម ហើយ បុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលអាចយកសម្ភារៈទាំងនោះ មកប្រើប្រាស់ដោយងាយស្រួល ។
- ទឹកគ្រប់គ្រាន់សម្រាប់កុមារងូត ឬ ជម្រះខ្លួន និង ទឹកសម្រាប់បោកគក់ឱ្យបានគ្រប់គ្រាន់រៀងរាល់ថ្ងៃ ។
- សម្ភារៈងូតទឹកដល់កុមារ ដូចជា សាប៊ូ កន្សែង ឬ ក្រមា ថ្នាំដុសធ្មេញ និង ច្រាស់ដុសធ្មេញផ្ទាល់ខ្លួន ។
- សម្ភារៈសម្រាប់ដំណេក ដូចជា កន្ទេល ខ្នើយ ភួយ មុង ជាដើម ។
- សម្លៀកបំពាក់ធម្មតា២សម្រាប់ ឯកសណ្ឋានសិស្ស១សម្រាប់ ស្បែកជើង និង ស្រោមជើង១គូ និង ស្បែកជើងផ្ទាត់១គូ រៀងរាល់៦ខែម្តង ក្នុងករណីបាត់បង់ ឬ ខូចខាត ត្រូវផ្តល់ឱ្យសារជាថ្មី ។
- ការណែនាំអំពីរបៀប ពេលវេលា និង មូលហេតុនៃការប្រើប្រាស់ថ្នាំ ដោយប្រើពាក្យសាមញ្ញស្របតាម

អាយុរបស់កុមារ ( ចំពោះកុមារដែលកំពុងទទួលការព្យាបាលជម្ងឺ ) ។

- ព័ត៌មាន និង ការយល់ដឹងអំពីគោលការណ៏នៃការសម្អាត អនាម័យផ្ទាល់ខ្លួន និង អនាម័យកន្លែងស្នាក់នៅ ព្រមទាំងការរៀបចំម្ហូបអាហារ ។

## ២. ការអភិវឌ្ឍន៍ផ្នែកសង្គមនិងផ្នែកវប្បធម៌

**មណ្ឌលត្រូវផ្តល់ឱ្យកុមារនូវ :**

- បរិស្ថានមួយដែលមាន ការថែទាំ ការយកចិត្តទុកដាក់ និងការគាំទ្រ ហើយ កុមារត្រូវមានសេរីភាពក្នុងការបង្ហាញពីអារម្មណ៏ គំនិតយោបល់ និង ការច្នៃប្រឌិតរបស់ខ្លួន ។
- ឱកាសចូលរួមក្នុងសកម្មភាព ផ្នែកសាសនា អប់រំ និង សកម្មភាពសង្គមផ្សេងៗ ដែលរៀបចំនៅក្នុងសហគមន៏ ឬ រៀបចំដោយមណ្ឌល ។
- ឱកាសចូលរួមក្នុងសកម្មភាពកំសាន្តផ្សេងៗ ជាមួយ កុមារមកពីសហគមន៏ជិតខាងមណ្ឌល ដែលសកម្មភាពកំសាន្តទាំងនោះ សមស្របទៅតាមអាយុរបស់កុមារ ។
- ពេលវេលាគ្រប់គ្រាន់ប្រកបដោយសុវត្ថិភាពសម្រាប់សកម្មភាព កីឡា ការលំហែកាយ ការកំសាន្តសកម្មភាពវប្បធម៌ សិល្បៈ ប្រពៃណី ។ល។ ហើយមណ្ឌលត្រូវបង្កលក្ខណៈឱ្យកុមារពិការបានចូលរួមក្នុងសកម្មភាពទាំងនោះផង ។
- សិទ្ធិយល់ដឹង និង សិទ្ធិរក្សាបាននូវអត្តសញ្ញាណរបស់ខ្លួន ដែលរួមមាន ឈ្មោះ ជនជាតិ សញ្ជាតិ សាសនា ភាសា និង សិទ្ធិសេរីភាពពេញលេញក្នុងការជ្រើសរើសជំនឿសាសនារបស់ខ្លួន ដោយគ្មានការប្រកាន់រើសអើង ព្រមទាំង គ្មានការបង្ខិតបង្ខំឱ្យកុមារកាន់សាសនាណាមួយ ដើម្បីជាថ្នូរនឹងការចិញ្ចឹមថែទាំឡើយ ។
- ការអប់រំទូន្មានឱ្យចេះគោរពជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ របស់កុមារដទៃទៀត ។
- ឱកាសទទួលបានការពិគ្រោះយោបល់ ជាមួយអ្នកដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ចំពោះកុមារ ដែលធ្លាប់រងគ្រោះពីការប៉ះទង្គិចផ្លូវចិត្ត ដូចជា ឪពុកម្តាយស្លាប់ អំពើហឹង្សា ឬ ការរំលោភបំពានផ្សេងៗ ជាដើម ។
- ការលើកទឹកចិត្តឱ្យចេះស្រលាញ់រាប់អានគ្នា ជាមួយកុមារដទៃទៀត ដោយគ្មានការបង្ខិតបង្ខំ និង រក្សាទំនាក់ទំនង ជាមួយ ឪពុកម្តាយបង្កើត សាច់ញាតិ ឬ មិត្តភ័ក្តិរបស់ខ្លួន និង សហគមន៏ ដោយស្ថិតក្រោមការឃ្លាំមើលរបស់មណ្ឌល ហើយប្រសិនបើ ទំនាក់ទំនងនោះ (ជួបផ្ទាល់ ឬ តាមទូរស័ព្ទ ) មិនបង្កឱ្យមានគ្រោះថ្នាក់ដល់កុមារទេ ។

- ការអនុញ្ញាតឱ្យមានទំនាក់ទំនង ជាមួយគ្រួសាររបស់ខ្លួន ទោះបី កុមារស្ថិតក្នុងស្ថានភាពអាចមានគ្រោះថ្នាក់ដោយសារគ្រួសាររបស់កុមារក៏ដោយ ប្រសិនបើជាបំណងប្រាថ្នារបស់កុមារ ឬ ជាឧត្តមប្រយោជន៍របស់កុមារ ក្នុងលក្ខខ័ណ្ឌដែលទំនាក់ទំនងនោះ ត្រូវធ្វើឡើងក្រោមការគ្រប់គ្រង ត្រួតពិនិត្យ ដោយបុគ្គលិក ។
- ឱកាសសម្រាប់ទៅលេងសាច់ញាតិបានតាមលទ្ធភាព ។
- សេរីភាពក្នុងការចេញចូលមណ្ឌល ដើម្បីធ្វើទំនាក់ទំនងជាមិត្តភាពជាមួយអ្នកជិតខាង ជាមួយមិត្តនៅសាលា ជាមួយសហគមន៍ និង ទទួលជួបគ្រួសារ ឬ មិត្តភ័ក្តិរបស់ខ្លួន ដែលមកសួរសុខទុក្ខក្នុងកំឡុងពេលមួយសមស្រប លើកលែងតែ ក្នុងស្ថានភាពពិសេសខ្លះ ដែលអាចធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់កុមារ ។

## ៣. ការសិក្សាអប់រំ

**មណ្ឌលត្រូវជួយឱ្យកុមារទទួលបាននូវ :**

- ការអប់រំជាមូលដ្ឋានយ៉ាងតិចប្រាំបួនឆ្នាំ ។
- ការអប់រំក្នុងប្រព័ន្ធ ឬ ក្រៅប្រព័ន្ធ ទាំងក្នុងសាលារដ្ឋ សាលាឯកជន ឬ ក្នុងមណ្ឌល ។ កម្មវិធីសិក្សាសម្រាប់ការអប់រំក្រៅប្រព័ន្ធ ត្រូវមានមេរៀនសម្រាប់ ការចេះអាន ចេះសរសេរ និង លេខនព្វន្តដើម្បីត្រៀមកុមារចូលរៀននៅសាលារដ្ឋ ឬ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ។
- ការជ្រើសរើស និង ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ខ្លួនផ្ទាល់ដោយមិនមានការរើសអើងអំពីភេទ ។
- ការអប់រំអំពី សិទ្ធិកុមារ សីលធម៌សង្គម អនាម័យ មេរោគអេដស៍ ជម្ងឺអេដស៍ សុខភាពទូទៅ សុខភាពបន្តពូជ និង ប្រធានបទផ្សេងៗ ទៀត ដែលស្របទៅតាមអាយុរបស់កុមារ ហើយ មានផលប្រយោជន៍ដល់ការអភិវឌ្ឍន៍របស់កុមារ ។
- ការបណ្តុះបណ្តាលអំពីវិធីការពារខ្លួន ដើម្បីគេចផុតពីភាពរងគ្រោះ ដោយសារ ការជួញដូរ ការរំលោភបំពាន និង ការកេងប្រវ័ញ្ចផ្សេងៗ ។
- សៀវភៅ និង សម្ភារៈផ្សេងៗ ដែលចាំបាច់សម្រាប់ការអប់រំ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួន និង កន្លែងស្ងប់ស្ងាត់សម្រាប់សិក្សា ។
- ការសិក្សាបន្ត ឬ ការបណ្តុះបណ្តាលវិជ្ជាជីវៈស្របតាម អាយុ ជម្រើសជំនាញរបស់កុមារ និង ស្របទៅតាមតម្រូវការទីផ្សារ ចំពោះកុមារដែលបានបោះបង់ចោលសាលា ហើយក្រោយមកពួកគេមានបំណងចង់បន្តការសិក្សា ។

## ៥. ការចូលរួម

**មណ្ឌលត្រូវផ្ដល់ឱ្យកុមារនូវ :**

- សិទ្ធិចូលរួមក្នុងការរៀបចំផែនការសម្រាប់អនាគតរបស់ខ្លួន ។
- សិទ្ធិក្នុងការបញ្ចេញទស្សនៈផ្ទាល់ខ្លួន និង សមហេតុសមផល ហើយដែលអាចសម្រេចបានសម្រាប់អនាគតរបស់ខ្លួន ។
- សិទ្ធិចូលរួមធ្វើសេចក្ដីសម្រេចដែលពាក់ព័ន្ធការងារគ្រួសារ និងការងារសមាហរណកម្ម ហើយការអនុវត្តន៍តាមមតិ ឬ យោបល់របស់កុមារ ត្រូវធានាសន្តិសុខ សុវត្ថិភាព និង សុខុមាលភាពរបស់កុមារ ។
- សិទ្ធិចូលរួម ក្នុងការរៀបចំការរស់នៅ ការផ្លាស់ប្ដូរទីកន្លែងស្នាក់នៅ ដូចជា សកម្មភាពប្រចាំថ្ងៃ ការរៀបចំកន្លែងដំណេក ការចូលមករស់នៅភ្លាម១ របស់កុមារផ្សេងទៀត ការផ្លាស់ប្ដូរ ឬ ការចាកចេញរបស់អ្នកថែទាំ ជាដើម ហើយការអនុវត្តន៍តាមមតិ ឬ យោបល់របស់កុមារ ត្រូវធានាសន្តិសុខ សុវត្ថិភាព និង សុខុមាលភាពរបស់កុមារ ។
- សិទ្ធិស្វែងយល់ និង យល់ដឹងអំពីបទដ្ឋានអប្បបរមាទាំងនេះ ព្រមទាំង អនុសញ្ញាស្ដីពីសិទ្ធិកុមារ ហើយមណ្ឌលត្រូវអប់រំកុមារឱ្យយល់ដឹងអំពីសិទ្ធិរបស់ពួកគេផ្ទាល់ ។
- សិទ្ធិពេញលេញក្នុងការទទួលបាននូវព័ត៌មាន ឯកសារ ឬ កំណត់ត្រាផ្ទាល់ខ្លួន រួមទាំង ជីវប្រវត្តិ និង កំណត់ត្រាផ្នែកវេជ្ជសាស្ត្រ ហើយ សំណុំឯកសារទាំងនោះ ត្រូវរក្សាជាការសម្ងាត់ ។
- ការគាំទ្រលើកទឹកចិត្តដល់ការបង្កើត និង ការរៀបចំផែនការអនាគតរបស់កុមារ ។
- ការជំរុញលើកទឹកចិត្តក្នុងការរៀបចំបង្កើតគណៈកម្មាធិការកុមារ ដើម្បីពិភាក្សាផ្លាស់ប្ដូរយោបល់នៅក្នុងមណ្ឌល អំពីបញ្ហាវិន័យ និង បទបញ្ជា សេចក្ដីសម្រេចចិត្ត និង បញ្ហានានា ដែលពាក់ព័ន្ធទៅនឹងការរស់នៅរបស់កុមារ ។
- ការអនុញ្ញាតឱ្យតំណាងគណៈកម្មាធិការកុមារ ធ្វើសេចក្ដីរាយការណ៍ជូនប្រធាន ឬ ក្រុមប្រឹក្សាភិបាលរបស់មណ្ឌលជាប្រចាំ ហើយមតិ ឬយោបល់របស់កុមារត្រូវយកមកពិចារណា នៅពេលធ្វើការសម្រេចចិត្ត ។
- ការណែនាំឱ្យចូលរួមធ្វើកិច្ចការផ្ទះប្រចាំថ្ងៃ ស្របទៅតាមអាយុ និង សមត្ថភាពរបស់កុមារ ហើយ កិច្ចការផ្ទះទាំងនោះ មិនមែនជាការងារនាំឱ្យមានគ្រោះថ្នាក់ ឬ ប៉ះពាល់ដល់សុខភាព និង ការអភិវឌ្ឍន៍របស់កុមារ ប៉ះពាល់ដល់ពេលវេលាសម្រាប់ ការអប់រំ ការលំហែកាយរបស់កុមារ ។ មណ្ឌលត្រូវធ្វើការគ្រប់គ្រង និង មើលថែទាំកុមារឱ្យបានគ្រប់ជ្រុងជ្រោយ នៅពេលកុមាររៀនមេរៀនបំណិនជីវិត ដូចជា

ការដាំទឹក ការដាំបាយ ជាដើម ។

- ការការពារពីភាពរើសអើងក្នុងការចូលរួមក្នុងដំណើរការប្រចាំថ្ងៃរបស់មណ្ឌល ។
- សិទ្ធិក្នុងការទទួលបាននូវព័ត៌មានផ្ទាល់ខ្លួន នៅពេលកុមារសំណូមពរក្នុងម៉ោងធ្វើការ ហើយ បើព័ត៌មាននោះអាចធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តរបស់កុមារ មណ្ឌលត្រូវពិគ្រោះយោបល់ជាមួយកុមារ នៅមុននិងក្រោយពេលដែលកុមារទទួលបានព័ត៌មានទាំងនោះ ។ ការផ្តល់ព័ត៌មានផ្ទាល់ខ្លួនរបស់កុមារ ជូនភ្ញៀវ អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីកុមារ ។ ការផ្តល់ជូនភ្ញៀវ នូវព័ត៌មានដែលមានការពាក់ព័ន្ធទៅនឹងការរំលោភបំពានលើកុមារ ស្ថានភាពមេរោគអេដស៍ និង ជម្ងឺអេដស៍របស់កុមារ និង ប្រវត្តិគ្រួសាររបស់កុមារ ត្រូវតែមានកម្រិត និង ត្រូវគិតដល់ឧត្តមប្រយោជន៍របស់កុមារ ។
- ពេលទំនេរជារៀងរាល់ថ្ងៃ ដើម្បី អានសៀវភៅ សារព័ត៌មាន ទស្សនាវដ្តី មើលទូរទស្សន៍ និង ស្តាប់វិទ្យុ ដែលសមស្របនឹងអាយុរបស់កុមារ ជាពិសេស ព័ត៌មានស្តីអំពីពិធីទាំងឡាយ ដែលទាក់ទងនឹងកុមារ ។ ប៉ុន្តែមិនត្រូវអនុញ្ញាតឱ្យកុមារទទួលព័ត៌មានពាក់ព័ន្ធ រូបភាព ឬ រឿងអាសអាភាស ឬ សម្ភារៈផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដល់កុមារឡើយ ។
- ការលើកទឹកចិត្តឱ្យចូលរួមនៅក្នុងថ្ងៃបុណ្យជាតិ និង អន្តរជាតិនានា ដូចជា បុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ បុណ្យអុំទូក បុណ្យចូលឆ្នាំសកល ទិវាកុមារអន្តរជាតិ ជាដើម និងសិទ្ធិឈប់សម្រាកក្នុងថ្ងៃបុណ្យជាតិ បុណ្យអន្តរជាតិ និង ពិធីបែបសាសនាផ្សេងៗ តាមការកំណត់របស់រាជរដ្ឋាភិបាល ។
- ការលើកទឹកចិត្តចូលរួមនៅក្នុងពិធីចែកសញ្ញាប័ត្របញ្ជាក់ការសិក្សាផ្សេងៗ ទស្សនកិច្ចសិក្សា និង សកម្មភាពផ្សេងៗទៀត ដែលទាក់ទងនឹង ការអប់រំ និង ការបណ្តុះបណ្តាលកុមារ ។
- ការអនុញ្ញាតឱ្យចូលរួមក្នុងពិធីផ្សេងៗ របស់គ្រួសារ ដូចជា ពិធីរៀបអាពាហ៍ពិពាហ៍ ឬ ពិធីបុណ្យសព ប្រសិនបើកុមារមានបំណងចង់ចូលរួម ហើយដែលពិធីនោះមិនបង្កអន្តរាយដល់សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ ។
- ការបំផុសលើកទឹកចិត្តឱ្យបាន រៀន និង ប្រើអត្តសញ្ញាណវប្បធម៌របស់ខ្លួន ព្រមទាំង ស្វែងយល់អំពីវប្បធម៌ផ្សេងៗទៀត របស់ពិភពលោក និង ត្រូវបង្កលក្ខណៈយ៉ាងហោចណាស់១ម៉ោង ក្នុងថ្ងៃ សម្រាប់ឱ្យកុមារហាត់ប្រាណ និង លេងល្បែងកំសាន្តផ្សេងៗនៅក្នុងទីធ្លាសមស្រប ។
- ការផ្តល់លទ្ធភាពឱ្យជ្រើសរើសសកម្មភាពនានា ដែលកុមារមានបំណងចង់ចូលរួម នឹងមិនត្រូវធ្វើសកម្មភាពណា ដែលមានលក្ខណៈបង្ខំចំពោះកុមារ លើកលែងតែ ជាភារកិច្ចប្រចាំថ្ងៃរបស់កុមារប៉ុណ្ណោះ ។

- ការអនុញ្ញាតឱ្យឈប់ពីការចូលរួមសកម្មភាពនានានៅពេលដែលសុខភាព សុវត្ថិភាព និង ការអភិវឌ្ឍន៍របស់កុមារមិនអំណោយផល ។
- ជំនួយផ្សេងៗ ដែលជាតម្រូវការរបស់កុមារពិការ ដើម្បីបង្កើនចលនា និង បង្កលក្ខណៈឱ្យកុមារបានចូលរួមក្នុងសកម្មភាពសិក្សា និង សកម្មភាពប្រចាំថ្ងៃ ។

## ៥. ការដាក់វិន័យចំពោះកុមារ

- ការដាក់វិន័យចំពោះកុមារ មិនត្រូវធ្វើឱ្យមានផលប៉ះពាល់ដល់ការអភិវឌ្ឍន៍ ផ្នែករាងកាយ ផ្លូវចិត្ត និង ផ្នែកសង្គមរបស់កុមារទេ ។ ការដាក់វិន័យដូចខាងក្រោមនេះ មិនត្រូវយកមកប្រើលើកុមារ ជាដាច់ខាត :
  - ការធ្វើទារុណកម្មលើរូបរាងកាយ
  - ការចាក់សោរបង្ខាំងកុមារឱ្យនៅតែឯង
  - ការចងកុមារ
  - ការមិនឱ្យទៅរៀន
  - ការបង្អត់អាហារ ឬ ទឹក ឬ ការមិនអនុញ្ញាតឱ្យកុមារទទួលទានដំណេក
  - ការដាក់ល័ក្ខខ័ណ្ឌឱ្យកុមារស្លៀកពាក់ប្លែកពីធម្មតា ឬ មិនសមស្រប
  - ការមិនឱ្យកុមារទទួលការព្យាបាលជម្ងឺ
  - ការប្រើឱ្យកុមារដាក់វិន័យលើកុមារដទៃទៀត
  - ការគំរាមកំហែង ឬ ការស្តីបន្ទោសកុមារ ដោយប្រើពាក្យមិនសមរម្យ និង អាសគ្រាម
  - ការដាក់ទណ្ឌកម្មឱ្យកុមារធ្វើការងារលើសពីកំលាំងកាយរបស់កុមារ ដូចជា ការបង្ខំឱ្យកុមារតូចៗ លើកវត្ថុធ្ងន់ៗ ជាដើម ។
- ត្រូវលើកទឹកចិត្តកុមារឱ្យមានឥរិយាបទល្អ សុភាពរាបសារ ស្លូតបូត មានសាមគ្គីភាព និង វិន័យថ្លៃថ្នូរ ។
- ការដាក់វិន័យលើកុមារអាចធ្វើទៅបានតែនៅពេលដែលកុមារមិនគោរពតាមបទបញ្ជាឬវិន័យប៉ុណ្ណោះ ។
- មិនត្រូវវាយតម្លៃ បន្ទុះបង្អាប់អំពីអាកប្បកិរិយារបស់កុមារនៅចំពោះមុខកុមារ ឬ មនុស្សផ្សេងទៀតឡើយ ។
- បុគ្គលិកក៏ត្រូវគោរពតាមបទបញ្ជា ឬ វិន័យរបស់មណ្ឌល និង ត្រូវធ្វើជាគំរូល្អចំពោះកុមារ ។

**ប្រការ ៤.-**

## ទំនាក់ទំនងមណ្ឌល និង អគារថែទាំកុមារ

### ១. មណ្ឌលត្រូវមាន :

- ទំហំផ្ទៃដីតូចបំផុតត្រឹម ២០០០ម៉ែត្រការ៉េ បើធំជាងនេះកាន់តែល្អ ចំពោះ ខេត្ត-ក្រុង និង ជនបទ ។ ចំពោះទីកន្លែងចង្អៀត ពិសេស ក្នុងរាជធានីភ្នំពេញ ត្រូវមានការចុះពិនិត្យ វាយតម្លៃ និង ការអនុញ្ញាត ជាមុនពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។
- បរិស្ថានល្អស្អាតជានិច្ច ទាំងក្នុងមណ្ឌល និង ជុំវិញមណ្ឌល ។
- សួនច្បារ ដងទង់ជាតិ និង ទីធ្លាសម្រាប់ឱ្យកុមារហាត់ប្រាណ លេងកំសាន្ត ឬ កីឡា ។ ក្នុងករណី មាន ស្រះ ត្រូវធ្វើរបងព័ទ្ធជុំវិញ ។
- ដីសម្រាប់ធ្វើសួនបន្លែ បំរើជីវភាពប្រចាំថ្ងៃរបស់មណ្ឌល និង បណ្តុះគំនិតឱ្យកុមារចេះស្រឡាញ់ ការងារ កសិកម្ម និង ចិញ្ចឹមសត្វ ។
- កន្លែងទុកដាក់ និង គ្រប់គ្រងសំរាម ឱ្យបានសមស្របជាប្រចាំ ។
- ប្រពន្ធ័លូ ដើម្បីបង្ហូរទឹកចេញ និង កន្លែងស្តុកទឹកដែលប្រើប្រាស់ចេញពីអគារ ។
- កន្លែងចិញ្ចឹមសត្វដាច់ដោយឡែកពីការិយាល័យ ធ្វើការ និង កន្លែងរស់នៅរបស់កុមារបើមាន ។
- របងសមរម្យ និងភ្លើងបំភ្លឺ ដើម្បីរក្សាសុវត្ថិភាពល្អសម្រាប់មណ្ឌល ។
- ក្លោងទ្វារ និង ស្លាកសញ្ញាឈ្មោះមណ្ឌលឱ្យបានត្រឹមត្រូវ ដោយមានសរសេរអាសយដ្ឋានទីកន្លែង ច្បាស់លាស់ ។

### ២. អគាររបស់មណ្ឌលត្រូវមាន :

- ស្ថានភាពល្អ សមស្របនឹងកម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។
- បង្អួចធំសមល្មម ដែលពន្លឺ និង ខ្យល់អាកាសអាចចេញចូលគ្រប់គ្រាន់ ។
- ប្រព័ន្ធការពារ ដើម្បីធានាសុវត្ថិភាពដល់កុមារ រួមទាំង ការរៀបចំប្រព័ន្ធចរន្តអគ្គិសនី និង ឧស្ម័ន ឱ្យបានត្រឹមត្រូវ និង ប្រព័ន្ធបង្ហូរទឹកកខ្វក់សល់ពីការប្រើប្រាស់ទៅកន្លែងស្តុក ។
- ធុងសម្រាប់ដាក់សំរាមឱ្យបានត្រឹមត្រូវ ។
- បង្គន់ និង បន្ទប់ទឹកសម្រាប់កុមារទាំងអស់រួមទាំងកុមារពិការផងដែរ ដែលអាចប្រើប្រាស់បានគ្រប់

ពេលវេលា និង ត្រូវមានបង្គន់ និង បន្ទប់ទឹកដោយឡែកសម្រាប់កុមារី ។

- បន្ទប់ដំណេក ដែលមានទំហំសមស្របសម្រាប់ដាក់គ្រែឱ្យ កុមារា និង កុមារី ទទួលទានដំណេកបាន ចំនួន ១០ ទៅ ១២ នាក់ ។
- ការរៀបចំឱ្យកុមារសម្រាកឱ្យសមស្របទៅតាមអាយុ និង ភេទរបស់កុមារ ។
- កន្លែងសម្រាប់ដាក់ទូ ដើម្បីដាក់សម្ភារៈប្រើប្រាស់ទាំងអស់របស់កុមារឱ្យបានត្រឹមត្រូវ ។
- បន្ទប់ធំទូលាយសមល្មមមួយសម្រាប់កុមាររៀនសូត្ររួមគ្នានៅពេលទំនេរ ដូចជា ភាសាបរទេស ឬ សម្រាប់ទស្សនាទូរទស្សន៍រួមគ្នា ។
- បន្ទប់ដាំបាយ កន្លែងទទួលទានបាយរួម សម្រាប់កុមារដែលស្នាក់នៅតាមផ្ទះនីមួយៗ ។
- បន្ទប់សម្រាប់ពិគ្រោះជម្ងឺ ក្នុងករណីកុមារមានជម្ងឺស្រាលៗ ។
- លក្ខណៈសម្បត្តិបង្កភាពងាយស្រួលសម្រាប់កុមារពិការប្រើប្រាស់ ។

## ជំពូកទី ៣
## ការគ្រប់គ្រងមណ្ឌលនិងការថែទាំកុមាររស់នៅក្នុងមណ្ឌល

### ប្រការ ៩. –

**ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងមណ្ឌលថែទាំកុមារមានដូចខាងក្រោម**

ជាតំណាងឱ្យស្ថាប័នរដ្ឋ អង្គការនានា ឬសប្បុរសជន អ្នកគ្រប់គ្រងមណ្ឌល :

- ត្រូវមានភារកិច្ចទទួលខុសត្រូវជាចម្បង គឺការពារសុវត្ថិភាពកុមារឱ្យរួចផុតអំពី អំពើហិង្សា ការកេងប្រវ័ញ្ច និង ការរំលោភបំពានផ្សេងៗ រួមទាំង ការទទួលខុសត្រូវផ្នែកសុខុមាលភាពលើរូបរាងកាយ ផ្លូវចិត្ត អារម្មណ៍ និងស្មារតីរបស់កុមារ ដែលស្ថិតក្រោមការថែទាំរបស់ខ្លួនផង ។
- ត្រូវធ្វើរបាយការណ៍ប្រចាំខែជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា តាមរយៈមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតសម្បទា ខេត្ត-ក្រុង រៀងរាល់ខែ ។ ដោយឡែក ចំពោះមណ្ឌលរបស់ក្រសួង ផ្ទាល់ត្រូវធ្វើរបាយការណ៍ មកក្រសួង តាមរយៈនាយកដ្ឋានសុខុមាលភាពកុមារ ជារៀងរាល់ខែ ។

- ត្រូវរៀបចំកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ ជាមួយអ្នកថែទាំកុមារពីមុន និង ជាមួយកុមារផង បើអាចធ្វើទៅបាននៅពេលផ្ទេរ ឬ ទទួលកុមារមករស់នៅក្នុងមណ្ឌល ។ កិច្ចសន្យានេះ ត្រូវមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានឃុំ ឬ សង្កាត់ ។
- ត្រូវជូនដំណឹងទៅអាជ្ញាធរឃុំ ឬ សង្កាត់ នៅពេលកុមារចាកចេញពីមណ្ឌល កុមារស្លាប់ កុមារត្រូវគេចាប់ពង្រត់ ឬ បាត់ខ្លួន ដើម្បីចាត់វិធានការសមស្រប ។ ជាមួយគ្នានេះ ក៏ត្រូវរាយការណ៍ជូន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាបន្ទាន់ ដើម្បីសហការចាត់ការបន្ត ។
- ត្រូវមានគោលការណ៍ណែនាំជាលាយល័ក្ខណ៍អក្សរ សម្រាប់រក្សាការសម្ងាត់អំពី ជីវប្រវត្តិ និង សំណុំឯកសារ ផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ ។
- ត្រូវអនុវត្តតាមគោលនយោបាយ និង នីតិវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាពិសេស គោលនយោបាយ និង បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ គោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យ និង ការវាយតម្លៃ ។
- ត្រូវមានគោលការណ៍ជាលាយល័ក្ខណ៍អក្សរ ដោយមានការយល់ព្រមពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីកំណត់អំពីនីតិវិធីសម្រាប់ជ្រើសរើសបុគ្គលិក សមាជិកគណៈគ្រប់គ្រង ឬ សមាជិកក្រុមប្រឹក្សាភិបាល អ្នកស្ម័គ្រចិត្ត និង អ្នកហាត់ការ ។
- ត្រូវបណ្តុះបណ្តាលទិសដៅការងារចំពោះបុគ្គលិក ដែលបានជ្រើសរើសឱ្យចូលបំរើការងារ និង ត្រូវមានរយៈពេល សាកល្បងការងារសម្រាប់បុគ្គលិកថ្មី ។
- ត្រូវមានបទបញ្ជាផ្ទៃក្នុង សម្រាប់អ្នកគ្រប់គ្រងបុគ្គលិក និង កុមារ ។ បទបញ្ជាផ្ទៃក្នុងនេះក៏ត្រូវកំណត់អំពីអាកប្បកិរិយាថ្លៃថ្នូរ ដើម្បីការពារកុមារពី ការរំលោភបំពាន ការពារអ្នកគ្រប់គ្រង និង ការពារបុគ្គលិក ពីការចោទប្រកាន់មិនត្រឹមត្រូវ ព្រមទាំង ត្រូវកំណត់ឱ្យច្បាស់នូវវិធានការខាងវិន័យ រួមទាំងវិធានការដែលអាចត្រូវធ្វើទៅតាមផ្លូវច្បាប់ក្នុងករណីដែល អ្នកគ្រប់គ្រងនិងបុគ្គលិកបានប្រព្រឹត្តខុស។
- ភ្ញៀវទាំងអស់ដែលចង់ចូលក្នុងមណ្ឌលថែទាំកុមារ ត្រូវមានការអនុញ្ញាតពីអ្នកគ្រប់គ្រងមណ្ឌលជាមុន ហើយ អ្នកគ្រប់គ្រងមណ្ឌលត្រូវចាត់បុគ្គលិកម្នាក់ ដើម្បីជូនភ្ញៀវគ្រប់ពេលវេលា ។
- ត្រូវមានចំនួនបុគ្គលិកតាមការចាំបាច់ដូចខាងក្រោម :
    + មានអ្នកថែទាំជាប្រចាំម្នាក់ សម្រាប់មើលថែទាំទារកអាយុក្រោម ១ឆ្នាំ ចំនួន ៣នាក់ ។
    + មានអ្នកថែទាំជាប្រចាំម្នាក់ សម្រាប់មើលថែទាំកុមារអាយុលើសពី ១ឆ្នាំ ដល់ ៣ឆ្នាំ ចំនួន ៥នាក់។
    + មានអ្នកថែទាំជាប្រចាំម្នាក់ សម្រាប់មើលថែទាំកុមារអាយុលើសពី ៣ឆ្នាំ ចំនួនពី១០ទៅ១៥នាក់។

+ មានអ្នកថែទាំជាប្រចាំម្នាក់ សម្រាប់មើលថែទាំ ទារកកំព្រា កុមារកំព្រា ដែលមានពិការភាពធ្ងន់ធ្ងរ ឬ កើតជម្ងឺអេដស៍ ចំនួន ២នាក់ ។

- ត្រូវប្រមូលព័ត៌មានស្តីពីកុមារឱ្យបានគ្រប់គ្រាន់ដែលទាក់ទងនឹង :
  + ឪពុកម្តាយ
  + សមាជិកផ្សេងៗទៀត របស់គ្រួសារ
  + អ្នកអាណាព្យាបាល
  + កុមាររងគ្រោះផ្ទាល់
  + អ្នកជិតខាង
  + អាជ្ញាធរ
- ត្រូវធ្វើការប៉ាន់ប្រមាណទៅលើស្ថានភាពគ្រួសារ និង មូលហេតុ ដែលកុមារត្រូវបាននាំទៅរស់នៅក្នុងមណ្ឌល ដូចជា កុមារងាយរងគ្រោះ កុមារត្រូវគេរំលោភបំពាន កុមារកំព្រា កុមារត្រូវគេបោះបង់ចោល កុមារផ្ទុកមេរោគអេដស៍ កុមារប្រើប្រាស់គ្រឿងញៀន ជាដើម ។
- ត្រូវពិចារណាព័ត៌មានស្តីពី ស្ថានភាពកុមារ ដែលទទួលបានពីការប៉ាន់ប្រមាណ ដើម្បីកសាងផែនការសម្រាប់អភិវឌ្ឍកុមារ ដែលក្នុងនោះមានទាំងគំរោងផែនការ ដូចជា ទំនាក់ទំនងជាមួយសមាជិកគ្រួសារ សាច់ញាតិ មិត្តភ័ក្តិ ឪពុកម្តាយធម៌ និង ស្នំកូនចិញ្ចឹម ជាដើម ។
- ត្រូវរក្សារាល់ព័ត៌មានដែលប្រមូលបានជាការសម្ងាត់ លើកលែងតែ ដើម្បីឧត្តមប្រយោជន៍របស់កុមារ ។
- ត្រូវវាយតម្លៃលទ្ធភាពនៃការធ្វើសមាហរណកម្ម ជារៀងរាល់ឆ្នាំ ។
- ត្រូវរៀបចំការចុះបញ្ជីកំណើតកុមារឱ្យបានឆាប់រហ័ស ប្រសិនបើកុមារមិនទាន់បានចុះបញ្ជីកំណើតទេ ។

**ប្រការ ៦. –**

**លក្ខណៈសម្បត្តិរបស់អ្នកថែទាំកុមារ និង អ្នកធ្វើម្ហូប :**

- អ្នកថែទាំកុមារត្រូវ :
  + មានអាយុចាប់ពី ២៥ឆ្នាំ ដល់ ៥៥ឆ្នាំ និង មានសុខភាពល្អ ។
  + មានកំរិតវប្បធម៌យ៉ាងតិចចប់បឋមសិក្សា ។
  + មានសីលធម៌ និង ចេះស្រឡាញ់ការងារក្នុងការចិញ្ចឹម និង ថែទាំកុមារ ។
- អ្នកថែទាំកុមារអាយុក្រោម ៦ឆ្នាំ ត្រូវជាស្ត្រី ឬ ប្តីប្រពន្ធស្របច្បាប់ ។
- អ្នកថែទាំកុមារត្រូវទទួលបាននូវការបណ្តុះបណ្តាលអំពី :

+ ការតម្រង់ទិស ដែលទាក់ទងអំពីជំនាញថែទាំកុមារ និង ការលើកកម្ពស់សមត្ថភាពជាប្រចាំ អំពីការអភិវឌ្ឍន៍របស់កុមារ និង ការថែទាំកុមារ ពិសេសការថែទាំកុមារងាយរងគ្រោះ ដូចជា ការបណ្តុះបណ្តាលអំពី ពិការភាព ការរំលោភបំពាន មេរោគអេដស៍ និង ជម្ងឺអេដស៍ ជាដើម ទន្ទឹមនឹងនេះ អ្នកថែទាំកុមារ ត្រូវទទួលបានការបំពាក់បំប៉ន អំពីការពិគ្រោះយោបល់ និង សារសំខាន់នៃការស្តាប់កុមារ និង របៀបស្តាប់កុមារ ។
+ សិទ្ធិជាមូលដ្ឋានរបស់កុមារ ច្បាប់ និង លិខិតបទដ្ឋាននានា ដែលទាក់ទងនឹងការរំលោភបំពានកុមារ ការមិនយកចិត្តទុកដាក់ និង ការកេងប្រវ័ញ្ចកុមារ ។
+ លក្ខណៈសម្គាល់សញ្ញាណនានា នៃការរំលោភបំពានកុមារ ។
+ ឥទ្ធិពលនានា នៃការរំលោភបំពាន ដែលអាចនឹងកើតមានចំពោះកុមារ និង ការចាត់វិធានការនានា នៅពេលដែល គេសង្ស័យថា ការរំលោភបំពានបានកើតឡើង ឬ កំពុងតែកើតឡើង ។

- អ្នកថែទាំកុមារត្រូវមានទំនាក់ទំនងល្អ និង ជំនឿទុកចិត្តពីកុមារ ដើម្បីបំពេញតម្រូវការផ្នែកចិត្តសាស្ត្ររបស់កុមារ និង ត្រូវរក្សាជាការសម្ងាត់នូវព័ត៌មានអំពីប្រវត្តិរបស់កុមារ ។
- អ្នកថែទាំកុមារ ត្រូវគោរព និង អនុវត្តតាមវេនការងារស្របតាមកិច្ចសន្យាការងារ និង បទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល ។
- អ្នកថែទាំកុមារ និង អ្នកធ្វើម្ហូប ត្រូវទទួលការបណ្តុះបណ្តាល និង មានការយល់ដឹងអំពីរបៀបផ្តល់របបអាហារូបត្ថម្ភ ដែលមានតុល្យភាព និង ប្រកបដោយអនាម័យ ។

## ប្រការ ៧.-

### អំពីបណ្តឹង និង កិច្ចការពារតាមផ្លូវច្បាប់

- អ្នកគ្រប់គ្រង និង បុគ្គលិកមណ្ឌលត្រូវធានាថា កុមារដឹងអំពីសិទ្ធិរបស់ខ្លួនក្នុង ការប្តឹង និង នីតិវិធីធ្វើពាក្យបណ្តឹង ។
- មណ្ឌលត្រូវរៀបចំឱ្យមានគោលការណ៍គ្រប់គ្រងឧប្បត្តិហេតុ ដើម្បីដោះស្រាយការចោទប្រកាន់ ឬ ការសង្ស័យអំពីការប្រព្រឹត្តខុសឆ្គងលើកុមារ ។
- គោលការណ៍គ្រប់គ្រងឧប្បត្តិហេតុនេះ រួមមាន ៖
  + នីតិវិធីដោះស្រាយបណ្តឹងតាមផ្លូវច្បាប់
  + ដំណើរការបញ្ជូនកុមារទៅរកសេវាពិគ្រោះយោបល់ និង សេវាផ្សេងៗទៀត
  + ការចាត់តាំងមន្ត្រីគ្រប់គ្រងករណី ៖ មន្ត្រីគ្រប់គ្រងករណី ត្រូវទទួលខុសត្រូវក្នុងការពិនិត្យមើល

ការស៊ើបអង្កេតការចោទប្រកាន់នីមួយៗទាំងស្រុង ដើម្បីធានាថាការស៊ើបអង្កេតនោះត្រូវធ្វើឡើងស្របទៅតាមដំណើរការផ្លូវច្បាប់ ។ លទ្ធផលនៃការស៊ើបអង្កេតមិនអាចផ្សះផ្សាតាមរយៈសំណងទេ ។

+ ការចាត់តាំងអ្នកសង្កេតការណ៍ឯករាជ្យដែលជាមនុស្សពេញវ័យ ដើម្បីផ្តល់ឱ្យកុមារនូវការឧបត្ថម្ភគាំទ្រនៅពេលធ្វើការស៊ើបអង្កេត ។

- នៅពេលដែលមានការចោទប្រកាន់កើតឡើង នៅក្នុងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល ឬ មណ្ឌលរបស់សប្បុរសជន មន្ត្រីគ្រប់គ្រងករណី គឺជាមន្ត្រីថ្នាក់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត-ក្រុង ។ ចំពោះមណ្ឌលរបស់រដ្ឋ នៅពេលដែលការចោទប្រកាន់កើតឡើង មន្ត្រីគ្រប់គ្រងករណីគឺជា មន្ត្រីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ។
- នៅពេលដាក់ពាក្យបណ្តឹង ឬ នៅពេលចាត់វិធានការតាមផ្លូវច្បាប់ មន្ត្រីគ្រប់គ្រងករណី ត្រូវទទួលខុសត្រូវក្នុងការការពារកុមារឱ្យមានសុវត្ថិភាព គេចផុតពីការអន្តរាយនានា ។
- គោលការណ៍គ្រប់គ្រងឧប្បត្តិហេតុនេះ ត្រូវធានាថា :

+ កុមារត្រូវស្គាល់ច្បាស់អំពី អ្នកដែលកុមារត្រូវរាយការណ៍ប្រាប់ នៅពេលមានជនណាម្នាក់បានប្រព្រឹត្តខុសឆ្គងមកលើខ្លួន ។

+ វិធានការផ្សេងៗ ត្រូវបានរៀបចំឡើង ដើម្បីការពារកុមារ និង ធ្វើយ៉ាងណាការពារកុមារមិនឱ្យទទួលរងគ្រោះជាថ្មីម្តងទៀត ។

+ មានការស៊ើបអង្កេតយ៉ាងហ្មត់ចត់ទៅលើការរំលោភបំពានដែលត្រូវបានសង្ស័យ ហើយ ត្រូវគោរពសិទ្ធិរបស់អ្នកដែលត្រូវគេចោទប្រកាន់ថាបានប្រព្រឹត្តល្មើស រហូតដល់លទ្ធផលការស៊ើបអង្កេតបានបញ្ជាក់ច្បាស់លាស់ ។

+ ការព្យួរការងារជាបណ្តោះអាសន្នត្រូវអនុវត្តចំពោះបុគ្គលិក ក្នុងករណី ដែលមានការចោទប្រកាន់ធ្ងន់ធ្ងរ រហូតដល់មានលទ្ធផលនៃការស៊ើបអង្កេត ។

- មណ្ឌលត្រូវទទួល និង ដោះស្រាយបណ្តឹងរបស់កុមារជាបន្ទាន់ និង ហ្មត់ចត់ ដោយផ្អែកតាមបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល និង ស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ។
- នៅពេលមានបណ្តឹង អ្នកគ្រប់គ្រងមណ្ឌលត្រូវជូនដំណឹងដល់កុមារ និង អ្នកសង្កេតការណ៍ឯករាជ្យដែលជាមនុស្សពេញវ័យអំពី របៀបដោះស្រាយបណ្តឹង ដំណើរការបណ្តឹង និង លទ្ធផលនៃបណ្តឹង ។
- សំណុំឯកសារបណ្តឹង និង ការស៊ើបអង្កេតត្រូវរក្សាជាការសម្ងាត់ ។

- នៅពេលបញ្ចប់ការស៊ើបអង្កេតបណ្តឹង មន្ត្រីគ្រប់គ្រងករណីត្រូវរាយការណ៍ជូនក្រសួង តាមរយៈប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត-ក្រុង ដើម្បីក្រសួងធ្វើការសម្រេចអំពី ការដាក់វិន័យ ឬ វិធានការ ផ្លូវច្បាប់លើបុគ្គលិក ឬ អ្នកគ្រប់គ្រងដែលពាក់ព័ន្ធ ។

## ប្រការ ៨. –

### ការរៀបចំ និង ការទុកដាក់ឯកសារ

- មណ្ឌលត្រូវកសាង និង រក្សាសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ ហើយសំណុំឯកសារទាំងនេះត្រូវបានរក្សាទុកនៅកន្លែង សម្ងាត់ មានសុវត្ថិភាព មានបុគ្គលិកម្នាក់ទទួលខុសត្រូវ ។
- សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ ត្រូវមានព័ត៌មានដូចខាងក្រោម :
  - ឈ្មោះពេញរបស់កុមារ និងឈ្មោះផ្សេងទៀតបើមាន រូបថត ភេទ ថ្ងៃខែឆ្នាំ និង ទីកន្លែងកំណើត ។
  - ឈ្មោះ អាយុ អាសយដ្ឋាន និង មុខរបររបស់ឪពុកម្តាយ បងប្អូនបង្កើត សាច់ញាតិផ្សេងទៀត និង អ្នកថែទាំពីមុន ។
  - កាលបរិច្ឆេទនិងមូលហេតុដែលកុមារចូលមករស់នៅក្នុងមណ្ឌលឬចាកចេញពីកន្លែងរស់នៅពីមុន ។
  - ព័ត៌មានផ្ទាល់របស់កុមារម្នាក់ៗពាក់ពន្ធ័កាលបរិច្ឆេទទៅលេងគ្រួសារ ឬគ្រួសារមកលេង ការសិក្សា អាកប្បកិរិយា ការដាក់វិន័យ និង មូលហេតុនៃការដាក់វិន័យ ស្ថានភាពជម្ងឺ ឬ គ្រោះថ្នាក់ផ្សេងៗ វិធីព្យាបាល ការចាក់ថ្នាំបង្ការ យោបល់របស់គ្រូពេទ្យដែលបានព្យាបាលពីមុន ។
  - កាលបរិច្ឆេទចេញពីមណ្ឌល និង ទីកន្លែង ដែលកុមាររស់នៅក្រោយពេលចេញពីមណ្ឌល ។
  - កិច្ចសន្យារបស់កុមារ របស់អ្នកថែទាំកុមារពីមុន ឬ របស់ឪពុកម្តាយ ។
  - សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាព និង ត្រូវបញ្ជូនសំណុំឯកសារនោះ មួយច្បាប់ទៅកន្លែងថ្មីដែលកុមារត្រូវទៅរស់នៅ ។
- ត្រូវធ្វើការប៉ាន់ប្រមាណស្ថានភាពគ្រួសារ ឬ ផ្ទះរបស់កុមាររស់នៅ ( មុនពេលចូលមណ្ឌល ) ដើម្បីបញ្ជាក់ថា តើអាចមានការរំលោភបំពានបានកើតឡើងក្នុងគ្រួសារ ឬ នឹងកើតឡើងក្នុងគ្រួសារកុមារនាពេលអនាគត ឬទេ ។
- ព័ត៌មានដែលបានមកពីការប៉ាន់ប្រមាណស្ថានភាពគ្រួសារ ឬ ផ្ទះរបស់កុមាររស់នៅ ត្រូវចុះនៅក្នុងផែនការករណី សម្រាប់កុមារម្នាក់ៗ រួមទាំង ផែនការសម្រាប់ទំនាក់ទំនងជាមួយសមាជិកគ្រួសារ ឬ មិត្តភ័ក្តិ ។

- ព័ត៌មានដែលទទួលបាន ពីឪពុកម្តាយ ពីសមាជិកគ្រួសារផ្សេងទៀត ពីកុមារ ពីអ្នកជិតខាង និង ពីអាជ្ញាធរមូលដ្ឋាន ត្រូវយកចិត្តទុកដាក់រក្សាជាការសម្ងាត់ ។

**ប្រការ ៩.-**

- ត្រូវយកចិត្តទុកដាក់ការពារអត្តសញ្ញាណរបស់កុមារ ទីកន្លែងរស់នៅរបស់កុមារ ឬ ព័ត៌មានផ្សេងៗ ដែលអាចកំណត់នូវអត្តសញ្ញាណរបស់កុមារ ។
- ក្នុងគ្រប់កាលៈទេសៈ រាល់ទំនាក់ទំនង និង ការផ្សព្វផ្សាយព័ត៌មាន អំពីកុមាររងគ្រោះ ត្រូវគោរព និង ការពារឧត្តមប្រយោជន៍របស់កុមារ និង ត្រូវបង្ហាញឱ្យឃើញថា ការរំលោភបំពានលើកុមារ គឺ ជាការខុសឆ្គង នឹងមិនត្រូវបង្ហាញថា កុមារជាជនរងគ្រោះឡើយ លើកលែងតែ ដើម្បីឧត្តមប្រយោជន៍របស់កុមារ និង មានការយល់ព្រមពីកុមារ ។

## ជំពូកទី ៤
## ការត្រួតពិនិត្យមណ្ឌលថែទាំកុមារ

**ប្រការ ១០.-**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អនុវត្តកម្មវិធីចុះត្រួតពិនិត្យការអនុវត្តន៍បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល មួយឆ្នាំម្តង ឬ លើសពីនេះ ក្នុងករណីចាំបាច់ ។
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង ត្រូវចុះត្រួតពិនិត្យជាប្រចាំលើការអនុវត្តន៍បទដ្ឋានអប្បបរមា សម្រាប់ការថែទាំកុមារក្នុងមណ្ឌល ចំពោះមណ្ឌលស្ថិតក្នុងសមត្ថកិច្ចខេត្ត-ក្រុង ដោយឡែកមណ្ឌលរបស់ក្រសួង ត្រូវត្រួតពិនិត្យដោយនាយកដ្ឋានសុខុមាលភាពកុមារ ។ ក្នុងករណីដែលមណ្ឌលមិនបានអនុវត្តតាម បទដ្ឋានអប្បបរមានេះ នាយកដ្ឋានសុខុមាលភាពកុមារ ឬ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិ សម្បទា ខេត្ត -ក្រុង ត្រូវធ្វើសេចក្តីជូនដំណឹងដល់មណ្ឌល ដោយផ្តល់រយៈពេល ៣ខែ មុននឹងចុះត្រួត ពិនិត្យម្តងទៀត ។
- ក្នុងករណី ដែលមណ្ឌលនៅតែពុំព្រមអនុវត្តតាមបទដ្ឋានអប្បបរមា ក្រោយរយៈពេល ៣ខែ នេះ នាយកដ្ឋានសុខុមាលភាពកុមារ ឬ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុងត្រូវធ្វើរបាយការណ៍ជូនមក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីផ្អាកដំណើរការមណ្ឌលជាបណ្តោះអាសន្ន ឬ ចាត់វិធានការតាមផ្លូវច្បាប់ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ១១. –**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១២. –**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត-ក្រុង ប្រធានមណ្ឌល ប្រធានអង្គការជាតិ ប្រធានអង្គការអន្តរជាតិ និងសប្បុរសជន ដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ។

**<u>ចំលងជូន</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **នៀ ផាញ់**
  " ដើម្បីជូនជ្រាប "
- គ្រប់ក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធ
  " ដើម្បីជ្រាប "
- ដូចប្រការ ១២ " ដើម្បីអនុវត្ត "
- ឯកសារ - កាលប្បវត្តិ